ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង ព្រហ្មទណ្ឌ

លេខ: ០៨

ចុះថ្ងៃទី២៥ - ០២ - ២០០០

សាលដីកា

លេខ: ០៧

ចុះថ្ងៃទី២៩ - ៣ - ២០០០

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មន្នី ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

៤ - លោក ស៊ិន ខឹម ចៅក្រម

៥ - លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី លោក ទ៉ាន់ បូរ៉ាត

តំណាងមហាអយ្យការឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់តុលាការកំពូល

ពីបទ ឆក់ ប្រព្រឹត្តកាលពីថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៩ នៅភូមិទី ៩ឃុំ- ស្រុក ខេត្តកំពង់ចាម បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ប៊ុច រិណ្ណៈ ហៅ ណិន ប៊ុទ្ធ " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣១ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ប៉ូលីសព្រៃដែនគោក ទីលំនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ គឹម ឆន " ស " ម្តាយឈ្មោះ ឡុង សាខន " រ " ប្រពន្ធឈ្មោះ ឡុង រីនរឿន មានកូន ០២ នាក់ ។ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៨ - ០១ - ២០០០ ។

មេធាវី លោក តា អ៊ាវ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហេម អ៊ឹម " ជាចុងបណ្តឹងសាទុក្ខ " ភេទ ស្រី អាយុ៤៣ឆ្នាំ ជាតិ ខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ភូមិទី ៩ ឃុំ- ស្រុក - ខេត្តកំពង់ចាម ។

មេធាវី គ្មាន

- តាមបណ្តឹងសាទុក្ខលេខ ១១ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់លោក គា អ៊ាវ មេធាវីការពារអោយជនជាប់ចោទឈ្មោះ ប៊ិច វណ្ណៈ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមដីកាផ្ទេរសមត្ថកិច្ចលេខ១០២ ចុះថ្ងៃទី ២៨-០១-២០០០ របស់តុលាការខេត្តកំពង់ចាម សំរេចផ្ទេររឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ០៤-០១-២០០០ ទៅអយ្យការអមតុលាការខេត្ត ដោយយល់ឃើញថា ការអង្កេតរឿងរដ្ឋប្បវេណីកន្លងមកមានលេចចេញនូវការក្លែងបន្លំឯកសារ ដែលប្រព្រឹត្តដោយឈ្មោះ ប៊ិច វណ្ណៈ ដូច្នេះក្នុងករណីនេះត្រូវដោះស្រាយរឿងព្រហ្មទណ្ឌជាមុនសិន ។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ៣៤ អក ចុះថ្ងៃទី២៨-០១-០០ របស់អយ្យការអមតុលាការខេត្តកំពង់ចាម សំរេចចោទប្រកាន់ឈ្មោះ ប៊ិច វណ្ណៈ ចៅ ឈិន ប៉ូឡូ ពីបទ ឆបោក ដោយយល់ឃើញថា ឈ្មោះ ប៊ិច វណ្ណៈ ឆ្លើយមិនស្មោះត្រង់ និងមានកែលិខិតចុះថ្ងៃទី ១៤-១១-៩៩ ក្នុងគោលបំណងបំបាត់សុំរុយពីកា កុំខ្វាស់បំណុល ។

- បានឃើញដីកាឃុំខ្លួនលេខ ២៨ អក ចុះថ្ងៃទី ២៨-០១-២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាម សំរេចឃុំខ្លួនឈ្មោះ ប៊ិច វណ្ណៈ ពីបទ ឆបោក

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់ឈ្មោះ - ប៊ិច វណ្ណៈ ចៅ ឈិន ប៉ូឡូ និង មេធាវី ដែលប្តឹងតវ៉ាពី ដីកាឃុំខ្លួនលេខ ២៨ អក ចុះថ្ងៃទី ២៨-០១-២០០០ របស់តុលាការខេត្តកំពង់ចាម ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-០២-២០០០ របស់មេធាវីលោក គា អ៊ាវ និងជនជាប់ចោទឈ្មោះ ប៊ិច វណ្ណៈ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - បើឈ្មោះ ប៊ិច វណ្ណៈ សុខចិត្តដាក់ប្រាក់ធានាខ្លួន អាចអនុញ្ញាតអោយនៅក្រៅឃុំបាន និងសំរេចបដិសេធលិខិតមោឃភាពដូចយល់ឃើញខាងលើ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៣-០២-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១-០២-២០០០ របស់ឈ្មោះ ប៊ិច វណ្ណៈ និង លោកមេធាវី គា អ៊ាវ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២ - តម្កល់ដីកាឃុំខ្លួនលេខ ២៨អក ចុះថ្ងៃទី ២៨-០១-២០០០ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ១១ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់លោក

តា អ៊ាំង មេធាវីការពារក្តីអោយជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០០ របស់ឈ្មោះ ប៊ិច វណ្ណះ ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញលិខិតបញ្ជាក់លេខ ១៣៧ ឃកច ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០០ របស់មេឃុំកំពង់ចាម ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនាការថា: ដោយបទល្មើសនេះជាបទល្មើសមជ្ឈិម តំណាងមហាអយ្យការយល់ឃើញថា អាចអោយជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្នបាន សូមតុលាការពិនិត្យនិងសំរេច ។

- បានស្តាប់អំណានលិខិតប្រគល់ និងទទួលទ្រព្យសម្បត្តិរវាងជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី ។

- បានស្តាប់អំណានលិខិតធានាសងប្រាក់បន្ថែមចំនួន ៥០០០ដុល្លារអាមេរិក របស់លោកទៀងតាម

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក តា អ៊ាំង មេធាវីការពារក្តីអោយជនជាប់ចោទ នៅពេលជំនុំជំរះថា : ការចាប់ឃុំខ្លួនប៊ិច វណ្ណះ របស់តុលាការខេត្តកំពង់ចាម គឺជាការខុសច្បាប់ ហើយខ្ញុំបាទបានទទូចសុំអោយតុលាការដោះលែងបាននៅក្រៅឃុំបណ្តោះអាសន្ន ដោយសំអាងហេតុថា :

១ - ដើមចោទឈ្មោះ ប៊ិច វណ្ណះ ជាចុងចម្លើយក្នុងរឿងរដ្ឋប្បវេណី ដែលដើមបណ្តឹងប្តឹងទាមទារលុយជំពាក់ករស៊ី ដោយផ្អែកលើកិច្ចសន្យា ដែលពុំទាន់ដល់កំណត់ត្រូវសង ។

២ - ការចាប់ខ្លួន ប៊ិច វណ្ណះ ពីបទ ឆបោក ដោយសំអាងថា " ប៊ិច វណ្ណះ ចែកលិខិត និងឆ្លើយមិនស្មោះត្រង់ " គឺជាការចោទមិនស្របតាមធាតុផ្សំបទល្មើស និងមិនស្របតាមមាត្រា ៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣ - ឈ្មោះ ប៊ិច វណ្ណះ ពុំដែលបង្កអោយមានការលំបាកដល់តុលាការឡើយ សូម្បីតែតុលាការផ្តាំទៅមាត់ទទេ ក៏ប៊ិច វណ្ណះ ចូលខ្លួនដែរ ។

៤ - ឈ្មោះ ប៊ិច វណ្ណះ មានប្រពន្ធកូន ផ្ទះសំបែង ទីលំនៅត្រឹមត្រូវ មានមុខងារតួនាទីក្នុងស្ថាប័នរដ្ឋត្រឹមត្រូវ និងមានមុខរបរដែលឈ្មោះ ហម អ៊ីម ធ្លាប់ទុកចិត្តរកស៊ីជាមួយគ្នារាប់ឆ្នាំមកហើយ ។ ម្យ៉ាងទៀតបទល្មើសដែលអយ្យការចោទ ក៏ពុំមែនជាបទល្មើសធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋ ឬបទល្មើសជាក់ស្តែងអ្វីដែរ ពិសេសពេលថ្មីនេះដើមបណ្តឹងរដ្ឋប្បវេណី និងកូនក្តីខ្ញុំបាទ មានការឯកភាពគ្នាផ្នែកសំណងខ្លះ ។

ហេតុនេះ ដោយសំអាងតាមសំអាងហេតុផលខាងលើ និងផ្អែកតាមមាត្រា១៩ ស្តីពីការចាប់ខ្លួន និងមាត្រា១៤ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ខ្ញុំបាទសូមអោយតុលាការជួយរកយុត្តិធម៌ -

និងលួចដោះលែងកូនក្តីខ្លួន ចេញទៅក្រៅឃុំបណ្តោះអាសន្នដោយអនុគ្រោះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងអយ្យការថា: សូមតម្កល់សេចក្តីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ការឆ្លើយរបស់ជនជាប់ចោទ លិខិតប្រគល់ទ្រព្យសម្បត្តិ ដើម្បីធានាការសុំនៅក្រៅឃុំ លិខិតសងប្រាក់បន្ថែម និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី ២៣-០២-២០០០ របស់មេធាវីការពារអោយជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកពិនិត្យជំនុំជំរះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ជនជាប់ចោទប៊ុច វណ្ណៈ ចៅ ជិន ប៉ុទ្ម ត្រូវបានចោទប្រកាន់អំពីបទល្មើសមជ្ឈិម ហើយមានគ្រួសារ មានអាស័យដ្ឋានត្រឹមត្រូវនិងមានមុខងារច្បាស់លាស់ បើតាមមាត្រា៦៤ ចំនុចទី១ នៃនីតិវិធីព្រហ្មទណ្ឌ មិនគប្បីឃុំខ្លួនបណ្តោះអាសន្នឡើយ ។

យល់ឃើញថា ជនជាប់ចោទ ប៊ុច វណ្ណៈ និងប្រពន្ធឡុង ថៃរឿន ព្រមទាំងអ្នកស្រីមរុំ បានឯកភាពគ្នាធ្វើលិខិតប្រគល់ ទទួលទ្រព្យសម្បត្តិ ដើម្បីធានាការសុំនៅក្រៅឃុំបណ្តោះអាសន្ន នាថ្ងៃទី ១៣-៣-២០០០ រួចហើយដែលគប្បីតុលាការកំពូលធ្វើការពិចារណា ។

យល់ឃើញថា ជនជាប់ចោទបានធ្វើសារភាពរួចហើយ រីឯដើមបណ្តឹងរដ្ឋប្បវេណី បានទទួលលិខិតបង្គាប់អោយធ្វើសារភាពហើយ ប៉ុន្តែពុំធ្វើសារភាពទេ ហើយក៏ពុំបានចូលរួមនាសវនាការនេះដែរ ដូច្នេះតុលាការកំពូលពិនិត្យជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៣-០២-២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ដោយហេតុនេះ

វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ១១ ចុះថ្ងៃទី ២៣-០២-២០០០ របស់មេធាវីការពារអោយជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈនូវសាលដីកាព្រហ្មទណ្ឌលេខ៤៧ចុះថ្ងៃទី២៣-០២-២០០០ របស់សាលាឧទ្ធរណ៍ទាំងស្រុង ។

៣ - លិខិតដោះលែងជនជាប់ចោទឈ្មោះ ប៊ុច ចំណុះ ចៅ ណិន ប៉ុខ្លូ អោយនៅក្រៅឃុំបណ្តោះអាសន្ន ១

៤ - បញ្ជូនសំណុំរឿងក្រុមព្រហ្មទណ្ឌលេខ ០៨ ចុះថ្ងៃទី ២៨ - ០២ - ២០០០ របស់តុលាការកំពូល ទៅតុលាការខេត្តកំពង់ចាមដើម្បីចាត់ការបន្តតាមនីតិវិធី ១

៥ - សាលដីកានេះប្រកាសនៅសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០០ ១